**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**អគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក**
**និងអាហ្វ្រិក-មជ្ឈឹមបូព៌ា**

**សេចក្តីប្រកាសព័ត៌មាន**
**«សម្រាប់ការផ្សព្វផ្សាយភ្លាម»**

# «រដ្ឋមន្ត្រីការបរទេសកម្ពុជា និងឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ពិភាក្សាការពង្រឹងទំនាក់ទំនងកម្ពុជា-អាមេរិក»

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៣ – ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **សុខ ចិន្តាសោភា** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា បានវាយតំលៃខ្ពស់ប្រកបដោយក្តីពេញចិត្តជ្រាលជ្រៅ ចំពោះការផ្លាស់ប្តូរទស្សនៈ និងកិច្ចពិភាក្សា "ប្រកបដោយផ្លែផ្កា" រយៈពេលពីរម៉ោង នៅក្នុងជំនួប កាលពីថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០២៣ រវាង **ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃកម្ពុជា និងគណៈប្រតិភូមន្ត្រីសភាសហរដ្ឋអាមេរិក ដឹកនាំដោយលោក Alex Carnes ក្រឡាបញ្ជីនៃក្រុមភាគច្រើនរបស់អនុគណៈកម្មាធិការស្តីពី ប្រតិបត្តិការរបស់រដ្ឋ និងបរទេស និងកម្មវិធីពាក់ព័ន្ធនានារបស់គណៈកម្មាធិការគ្រប់គ្រង និងបែងចែកថវិកាជាតិ របស់ព្រឹទ្ធសភាអាមេរិក ដោយបានគូសបញ្ជាក់ថា ជំនួបនេះនឹងនាំទៅដល់ការបង្កើនការយល់ដឹងរវាងប្រទេសទាំងពីរ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងឯកឧត្តមឯកអគ្គរដ្ឋទូត បានអះអាងសាជាថ្មី នៅក្នុងជំនួបសម្តែងការគួរសមនាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ ពីការប្តេជ្ញាចិត្តក្នុងការពង្រឹងបន្ថែមទៀតនូវចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ និងបានពិភាក្សាលើទិដ្ឋភាពមួយចំនួននៃការលើកកម្ពស់ទំនាក់ទំនងទ្វេភាគី។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ ចិន្តាសោភា បានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះជំនួយរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលបានគាំទ្រដល់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចនៅកម្ពុជា។ ឯកឧត្តមឯកអគ្គរដ្ឋទូត Murphy បានថ្លែងរំលឹកដោយការកោត

អាសយដ្ឋានៈ លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

សរសើរចំពោះការរួមចំណែកយ៉ាងសកម្មរបស់កម្ពុជា ក្នុងតួនាទីជាប្រធានអាស៊ាន ក្នុងការលើកកម្ពស់ទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-អាមេរិក ទៅជា "ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ"។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ ចិន្តាសោភា បានជម្រាបឯកឧត្តមឯកអគ្គរដ្ឋទូត Murphy អំពីគម្រោងកាលវិភាគរបស់**ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិតនាយករដ្ឋមន្ត្រីកម្ពុជា** ចូលរួមក្នុងជំនួបធុរកិច្ចជាមួយក្រុមហ៊ុនអាមេរិកមួយចំនួន ដែលនឹងរៀបចំឡើងដោយក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ាន ដើម្បីពិភាក្សាពីឱកាសធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសឯកឧត្តមនាយករដ្ឋមន្ត្រីអញ្ជើញចូលរួមកិច្ចប្រជុំមហាសន្និបាតអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក នាពេលខាងមុខ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងឯកឧត្តមឯកអគ្គរដ្ឋទូត ក៏បានពិភាក្សាគ្នាផងដែរ អំពីការរៀបចំជំនួបរវាង**ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិតនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត** និងលោកជំទាវ Victoria Nuland អនុរដ្ឋមន្ត្រីការបរទេសស្តីទីរបស់សហរដ្ឋអាមេរិក នៅអំឡុងពេលនៃកិច្ចប្រជុំមហាសន្និបាតអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងឯកឧត្តមឯកអគ្គរដ្ឋទូត ក៏បានពិភាក្សាគ្នាអំពីកិច្ចសហប្រតិបត្តិការក្នុងវេទិកាពហុភាគី ជាពិសេសក្នុងក្របខ័ណ្ឌអាស៊ាន និងអង្គការសហប្រជាជាតិ ព្រមទាំងបានផ្លាស់ប្តូរយោបល់លើបញ្ហាតំបន់និងអន្តរជាតិមួយចំនួនដែលមានផលប្រយោជន៍រួម។ ឯកឧត្តមទាំងពីររូបបានសម្តែងក្តីសោមនស្សរួមគ្នាចំពោះដំណើរការយ៉ាងរលូន និងកិច្ចសហការដ៏ល្អរវាងប្រទេសទាំងពីរ ក្រោមក្របខ័ណ្ឌភាពជាដៃគូមេគង្គ-អាមេរិក។

នៅក្នុងជំនួបនោះដែរ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ ចិន្តាសោភា ក៏បានសម្តែងនូវអំណរគុណចំពោះការជូនពរ និងការអបអរសាទរដ៏កក់ក្តៅរបស់ឯកឧត្តមឯកអគ្គរដ្ឋទូត Murphy ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ចំពោះការតែងតាំងនូវតួនាទីថ្មី និងបានជានាចំពោះឯកឧត្តមឯកអគ្គរដ្ឋទូតនូវការបន្តទំនាក់ទំនងការងារដ៏ល្អនាបច្ចុប្បន្នរវាងក្រសួងនិងស្ថានទូត។ ឯកឧត្តមទាំងពីររូបបានបង្ហាញពីសុទិដ្ឋិនិយមចំពោះអនាគតនៃទំនាក់ទំនងរវាងប្រទេសទាំងពីរ៕

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖
ឈ្មោះ៖ អាន សុខខឿន
ទូរស័ព្ទ៖ 069 567 169 ( Telegram និងWhatsApp )
អ៊ីមែល៖ mfaic@mfaic.gov.kh